# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ០០៤ គ.ជ.ប.ស.ជ.ណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ និងការទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ សម្រាប់ការបោះឆ្នោតលើកទី១ (ការបោះឆ្នោតឡើងវិញ) ដើម្បីជ្រើសរើសក្រុមប្រឹក្សាក្រុងអរិយក្សត្រ ក្រុងសំពៅពូន នៃខេត្តកណ្តាល ក្រុងឧដុង្គម៉ែជ័យ ស្រុកសាមគ្គីមុនីជ័យ នៃខេត្តកំពង់ស្ពឺ និងស្រុកអូរគ្រៀងសែនជ័យ នៃខេត្តក្រចេះ ឆ្នាំ២០២៣

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (**គ.ជ.ប**) សូមជម្រាបជូនដំណឹងជាសាធារណៈដល់គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិទាំងអស់ ស្តីពីការដាក់ និងការទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ដូចខាងក្រោម៖

**I. ការដាក់ និងការទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ**

**១. ការដាក់ និងការទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ សម្រាប់ការចុះឈ្មោះបោះឆ្នោត**

- កាលបរិច្ឆេទនៃការដាក់ និងការទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ **ចាប់ផ្តើមពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ បញ្ចប់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣**។
- គណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយមានសិទ្ធិចាត់តាំងភ្នាក់ងាររបស់ខ្លួន ២ (ពីរ) រូប ភ្នាក់ងារពេញសិទ្ធិ ១ (មួយ) រូប និងភ្នាក់ងារបម្រុង ១ (មួយ) រូប ដើម្បីសង្កេតមើលការចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ នៃក្រុង ស្រុក។
- ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយត្រូវចុះហត្ថលេខាដោយប្រធាន ឬតំណាងគណបក្សនយោបាយដែលទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយ។ ការផ្ទេរសិទ្ធិនេះ មិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តឡើយ លើកលែងតែក្នុងលិខិតផ្ទេរសិទ្ធិនោះមានខ្លឹមសារអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្ត។
- គណបក្សនយោបាយ ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងាររបស់ខ្លួន តាមទម្រង់បែបបទលេខ ១០០៧ (ទ.១០០៧) ទៅគណៈកម្មការរៀបចំការបោះឆ្នោត (គ.ខ.ប) នៃខេត្តសាមីពាក់ព័ន្ធ។
- ពាក្យសុំចុះឈ្មោះភ្នាក់ងារ ទ. ១០០៧ ត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃ នៅ គ.ខ.ប ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តក្រចេះ ឬអាចទាញយកពីគេហទំព័ររបស់ គ.ជ.ប (www.nec.gov.kh)។
- ភ្នាក់ងារគណបក្សនយោបាយសង្កេតមើលការចុះឈ្មោះបោះឆ្នោតត្រូវពាក់បណ្ណសម្គាល់ដែលចេញដោយ គ.ខ.ប ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តក្រចេះ។

### ២. ការដាក់ និងការទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ សម្រាប់ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត

- កាលបរិច្ឆេទនៃការដាក់ និងការទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ **ចាប់ផ្ដើមពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ បញ្ចប់ថ្ងៃទី២ ខែមីនា ឆ្នាំ២០២៣**។
- គណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុងអរិយក្សត្រ ក្រុងសំពៅពូន នៃខេត្តកណ្ដាល ក្រុងឧដុង្គម៉ែជ័យ ស្រុកសាមគ្គីមុនីជ័យ នៃខេត្តកំពង់ស្ពឺ និងស្រុកអូរគ្រៀងសែនជ័យ នៃខេត្តក្រចេះ មានសិទ្ធិចាត់តាំងភ្នាក់ងាររបស់ខ្លួន ចំនួន ២ (ពីរ) រូប ភ្នាក់ងារពេញសិទ្ធិ ចំនួន ១ (មួយ) រូប និងភ្នាក់ងារបម្រុង ចំនួន ១ (មួយ) រូប ដើម្បីសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនៃក្រុង ស្រុកដែលខ្លួនឈរឈ្មោះ។
- ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ ត្រូវចុះហត្ថលេខាដោយប្រធាន ឬតំណាងគណបក្សនយោបាយ ដែលទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយ។ ការផ្ទេរសិទ្ធិនេះ មិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តឡើយ លើកលែងតែក្នុងលិខិតផ្ទេរសិទ្ធិនោះមានខ្លឹមសារអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្ត។
- គណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងាររបស់ខ្លួនទៅ គ.ខ.ប នៃខេត្តសាមីពាក់ព័ន្ធ។
- ពាក្យសុំចុះឈ្មោះភ្នាក់ងារ ទ. ១០០៧ ត្រូវបានផ្ដល់ជូនដោយឥតគិតថ្លៃ នៅ គ.ខ.ប ខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ និងខេត្តក្រចេះ ឬអាចទាញយកពីគេហទំព័ររបស់ គ.ជ.ប (www.nec.gov.kh)។
- ភ្នាក់ងារគណបក្សនយោបាយដែលសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនៃក្រុងអរិយក្សត្រ ក្រុងសំពៅពូន នៃខេត្តកណ្ដាល ក្រុងឧដុង្គម៉ែជ័យ ស្រុកសាមគ្គីមុនីជ័យ នៃខេត្តកំពង់ស្ពឺ និងស្រុកអូរគ្រៀងសែនជ័យ នៃខេត្តក្រចេះ ត្រូវពាក់បណ្ណសម្គាល់ដែលចេញដោយ គ.ខ.ប ខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ និងខេត្តក្រចេះ។

## II. ការដាក់ និងការទទួលពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ

### ១. ការដាក់ និងការទទួលពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ

- កាលបរិច្ឆេទនៃការដាក់ និងការទទួលពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍ជាតិ **ចាប់ផ្ដើមពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ បញ្ចប់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣**។
- សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលជាតិដែលមានបំណងចូលរួមសង្កេតការណ៍ ត្រូវបំពេញពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ឱ្យបានត្រឹមត្រូវ និងត្រូវដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេត-ការណ៍របស់ខ្លួននៅទីស្ដីការ គ.ជ.ប រៀងរាល់ម៉ោងធ្វើការ **ព្រឹកចាប់ពីម៉ោង ៧:០០ ដល់ម៉ោង ១១:៣០ នាទី និងរសៀលចាប់ពីម៉ោង ១៤:០០ ដល់ម៉ោង ១៧:៣០ នាទី (ការិយាល័យកិច្ចការគណបក្សនយោបាយ និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ជាន់ទី៩)**។
- គំរូពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ មានផ្ដល់ជូនដោយឥតគិតថ្លៃនៅទីស្ដីការ គ.ជ.ប ឬអាចទាញយកពីគេហទំព័ររបស់ គ.ជ.ប (www.nec.gov.kh)។
- អ្នកសង្កេតការណ៍ជាតិដែលបានទទួលស្គាល់ និងអនុញ្ញាតជាផ្លូវការពី គ.ជ.ប រួចហើយ មានសិទ្ធិសង្កេតមើលការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ហើយត្រូវពាក់បណ្ណសម្គាល់ខ្លួនដែលចេញដោយ គ.ជ.ប តាមរយៈ គ.ខ.ប។

**២. ការដាក់ និងការទទួលពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ**

- កាលបរិច្ឆេទនៃការដាក់ និងការទទួលពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍អន្តរជាតិ **ចាប់ផ្ដើមពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ បញ្ចប់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣**។
- អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដែលមានបំណងចូលរួមសង្កេតការណ៍ ត្រូវបំពេញពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ឱ្យបានត្រឹមត្រូវ និងត្រូវដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍របស់ខ្លួននៅទីស្ដីការ គ.ជ.ប រៀងរាល់ម៉ោងធ្វើការ **ព្រឹកចាប់ពីម៉ោង ៧:០០ ដល់ម៉ោង ១១:៣០ នាទី និងរសៀលចាប់ពីម៉ោង ១៤:០០ ដល់ម៉ោង ១៧:៣០ នាទី (ការិយាល័យកិច្ចការគណបក្សនយោបាយ និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ជាន់ទី៩)**។
- គំរូពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ មានផ្ដល់ជូនដោយឥតគិតថ្លៃនៅទីស្ដីការ គ.ជ.ប ឬអាចទាញយកពីគេហទំព័ររបស់ គ.ជ.ប (www.nec.gov.kh)។
- អ្នកសង្កេតការណ៍អន្តរជាតិដែលបានទទួលស្គាល់ និងអនុញ្ញាតជាផ្លូវការពី គ.ជ.បរួចហើយមានសិទ្ធិសង្កេតមើលដំណើរការបោះឆ្នោតទាំងមូល ឬតាមដំណាក់កាល និងគ្រប់ទីកន្លែងទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ការបោះឆ្នោតលើកទី១ (ការបោះឆ្នោតឡើងវិញ) ដើម្បីជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ដែលបំបែក និងបង្កើតថ្មី នៃខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ និងខេត្តក្រចេះ ហើយត្រូវពាក់បណ្ណសម្គាល់ខ្លួនដែលចេញដោយ គ.ជ.ប។

**III. សំណូមពរ**

បន្ទាប់ពីដំណើរការបោះឆ្នោតបានចប់សព្វគ្រប់ហើយ សាមីអង្គការសង្កេតការណ៍ទាំងឡាយត្រូវផ្ដល់របាយការណ៍ជាលាយលក្ខណ៍អក្សរស្ដីពីការសង្កេតឃើញ និងសេចក្ដីសន្និដ្ឋានរបស់ខ្លួននៅក្នុងដំណើរការបោះឆ្នោតជូន គ.ជ.ប។

គ.ជ.ប សង្ឃឹមថា គ្រប់គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ គ.ខ.ប ខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ និងខេត្តក្រចេះ នឹងយកចិត្តទុកដាក់សហការឱ្យបានល្អ ដើម្បីជំរុញឱ្យដំណើរការបោះឆ្នោតលើកទី ១ (ការបោះឆ្នោតឡើងវិញ) ដើម្បីជ្រើសរើសក្រុមប្រឹក្សាក្រុងអរិយក្សត្រ ក្រុងសំពៅពូន នៃខេត្តកណ្ដាល ក្រុងឧដុង្គម៉ែជ័យ ស្រុកសាមគ្គីមុនីជ័យ នៃខេត្តកំពង់ស្ពឺ និងស្រុកអូរគ្រៀង-សែនជ័យ នៃខេត្តក្រចេះ ឆ្នាំ២០២៣ ប្រព្រឹត្តទៅប្រកបដោយជោគជ័យ។

ថ្ងៃសុក្រ ៧រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**